អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍

# សិក្ខាសាលា

## ស្តីពីការអភិវឌ្ឍអាជីពការងារ

២៨ មករា ២០០៧

Carrier Development Workshop
Organized by ARD
1

## គោលបំណងសិក្ខាសាលា

ដើម្បីផ្តល់ឱកាសដល់សិស្ស-និស្សិត និងយុវជនកម្ពុជា អោយទទួលបាននូវការស្វែងយល់អំពី :

១. ស្ថានភាពតំរូវការទីផ្សារការងារនាពេលបច្ចុប្បន្ន

២. វិធីសាស្ត្រ និងរបៀបស្វែងរកការងារប្រកបដោយជោគជ័យ

៣. វិធីសាស្ត្រ និងរបៀបនូវការអភិវឌ្ឍន៍អាជីពការងាររបស់ខ្លួន

Carrier Development Workshop
Organized by ARD
2

## លទ្ធផលរំពឹងទុក

នៅក្រោយពីបញ្ចប់សិក្ខាសាលាស្តីពីការអភិវឌ្ឍន៍អាជីពការងាររយៈពេលមួយព្រឹកនេះ និស្សិតសរុបចំនួន៣០នាក់មកពីមហាវិទ្យាល័យនានាក្នុងព្រះរាជា-ណាចក្រកម្ពុជា នឹងយល់ដឹងបានច្បាស់លាស់ពី :

១. ប្រភព និងប្រភេទការងារដែលមាននាពេលបច្ចុប្បន្ន

២. ការសិក្សាពីដំណើងជ្រើសរើសបុគ្គលិក និងកត្តាផ្សេងៗដើម្បីពិចារណាក្នុងការដាក់ពាក្យ

៣. វិធីសាស្ត្រ និងរបៀបសរសេរប្រវត្តិរូបសង្ខេប និងលិខិតដាក់ពាក្យធ្វើការងារ

Carrier Development Workshop
Organized by ARD
3

៤. ការត្រៀមខ្លួនដើម្បីប្រកួតប្រជែង (សំភាសន៏)

៥. ចំនុចសំខាន់ៗ និងអាកប្បកិរិយាដែលត្រូវប្រកាន់យកក្នុងពេលសំភាសន៏

៦. ចំនុចសំខាន់ៗដើម្បីអោយអាជីពការងារទទួលបានជោគជ័យ និងមានការអភិវឌ្ឍន៏ ។

Carrier Development Workshop
Organized by ARD
4

## ប្រភព និងប្រភេទការងារ

១. អង្គការជាតិ អន្តរជាតិ

- ☛ ការងារអភិវឌ្ឍន៏សហគមន៏ (កសិកម្មចំរុះ, សុខភាព និងអនាម័យ, ការអប់រំ, គំរោងហេដ្ឋារចនាសម្ព័ន្ធនានា...)
- ☛ ការតស៊ូមតិ (សិទ្ធិមនុស្ស, លទ្ធិប្រជាធិបតេយ្យ, ការលើកកំពស់តួនាទីស្ត្រី និងកុមារ, ការប្រឆាំងអំពើពុករលួយ, អភិបាលកិច្ចល្អ, ការអភិរក្សធនធានធម្មជាតិ និងបរិស្ថាន...)
- ☛ ការពង្រឹងសមត្ថភាព (សំរាប់សិស្ស និស្សិត ប្រជាពលរដ្ឋទូទៅ)

Carrier Development Workshop
Organized by ARD
5

២. ស្ថាប័នគ្រឹះស្ថានឧត្តមសិក្សា (សាកលវិទ្យាល័យ, វិទ្យាស្ថាន, មជ្ឈមណ្ឌលបណ្តុះបណ្តាល...)

៣. ក្រុមហ៊ុន (ទេសចរណ៏, សំណង់, នាំចេញ-នាំចូល, ឱសថ...)

៤. រោងចក្រ-សហគ្រាស (សំលៀកបំពាក់, ស្បែកជើង, ស្រាបៀរ, កែច្នៃគ្រឿងឧបភោគ-បរិភោគ...)

៥. សណ្ឋាគារ, ភោជនីយដ្ឋាន, ហាងទំនិញ, ផ្សារទំនើប, មជ្ឈមណ្ឌលពតិមានវិទ្យា, ហាងជំនួញផ្សេងៗ... ។

Carrier Development Workshop
Organized by ARD
6

## ជំនាញសំខាន់ៗដើម្បីរកការងារ :

ការអភិវឌ្ឍន៍, កសិកម្ម, សង្គមវិទ្យា, ពត៌មានវិទ្យា, សុខាភិបាល, ការគ្រប់គ្រង, ធនធានធម្មជាតិ និងបរិស្ថាន, រដ្ឋបាល និងហិរញ្ញវត្ថុ, ច្បាប់ (សិទ្ធិមនុស្ស, លទ្ធិប្រជាធិបតេយ្យ, ច្បាប់ផ្សេងៗ), វិចិត្រសិល្បៈ, វិស្វករសំណង់, ទីផ្សារ, ទេសចរណ៍...។

Carrier Development Workshop
Organized by ARD
7

## ជំនាញសំខាន់ៗដើម្បីរកការងារ :

ការអភិវឌ្ឍន៍, កសិកម្ម, សង្គមវិទ្យា, ពត៌មានវិទ្យា, សុខាភិបាល, ការគ្រប់គ្រង, ធនធានធម្មជាតិ និងបរិស្ថាន, រដ្ឋបាល និងហិរញ្ញវត្ថុ, ច្បាប់ (សិទ្ធិមនុស្ស, លទ្ធិប្រជាធិបតេយ្យ, ច្បាប់ផ្សេងៗ), វិចិត្រសិល្បៈ, វិស្វករសំណង់, ទីផ្សារ, ទេសចរណ៍...។

Carrier Development Workshop
Organized by ARD
8

## ដំណាក់កាលសំខាន់ៗនៅក្នុងការស្វែងរកការងារ

១. ស្វែងរក និងសិក្សាពីដំណឹងជ្រើសរើសបុគ្គលិក
២. ការរៀបចំប្រវត្តិរូបសង្ខេប និងលិខិតដាក់ពាក្យសុំការងារ
៣. ការត្រៀមខ្លួនដើម្បីសំភាសន៍ និងការសំភាសន៍
៤. ការអនុវត្តការងារដើម្បីអោយមានការអភិវឌ្ឍន៍

Carrier Development Workshop
Organized by ARD
9

## ការស្វែងរក និងសិក្សាពីដំណឹងជ្រើសរើសបុគ្គលិក

- តើមានចំនុចសំខាន់ៗអ្វីខ្លះនៅក្នុងសេចក្តីជូនដំណឹងជ្រើសរើសបុគ្គលិក?

១. តំណែងការងារ និងអង្គភាពការងារ
២. ការបរិយាយពីការងារ (Responsibility)
៣. លក្ខ័ណ្ឌសំរាប់ធ្វើការងារ (Qualification)
៤. លក្ខ័ណ្ឌនៃការដាក់ពាក្យ (កាលបរិច្ឆេទចុងក្រោយសំរាប់ ដាក់ពាក្យ, ទីកន្លែង រឺមធ្យោបាយសំរាប់ដាក់ពាក្យ) ។

Carrier Development Workshop
Organized by ARD
10

- មុននឹងសំរេចចិត្តដាក់ពាក្យ បេក្ខជនត្រូវអាន និងពិចារណាអោយបានដិតដល់ទៅលើចំនុចសំខាន់ទាំងបួនខាងលើ ជាពិសេសចំនុចការបរិយាយ និងលក្ខ័ណ្ឌការងារ (Responsibility and Qualification)
- ដើម្បីជាជំនួយនៅក្នុងការសំរេចចិត្តបានត្រឹមត្រូវ ដើម្បីដាក់ពាក្យធ្វើការងារ បេក្ខជនត្រូវសួរ និងឆ្លើយដោយខ្លួនឯង នូវសំណួរសំរាប់ឆ្លុះបញ្ចាំងដូចខាងក្រោម :

- តើតំណែងការងារនេះ វាសមស្របទៅនឹងចំណេះដឹង និងបទពិសោធន៍ របស់ខ្ញុំដែលមានរឺទេ?

- តើខ្ញុំអាចបំពេញការងារនេះបានជោគជ័យ តាមអ្វីដែលជាការទទួលខុសត្រូវដូចមានចែងនៅក្នុងការបរិយាយការងារដែររឺទេ?

Carrier Development Workshop
Organized by ARD
11

- តើខ្ញុំមានលក្ខណៈសម្បត្តិច្រើន រឺឆ្លើយតបបានប៉ុន្មានចំនុចដែលត្រូវការសំរាប់ការងារនេះដែររឺទេ?

- តើការងារនេះវាពិតជាអាចជួយអោយខ្ញុំអាចចាប់ផ្តើម រឺអភិវឌ្ឍន៍ រឺទេ?

- តើអង្គការ រឺក្រុមហ៊ុននោះ ធ្វើសកម្មភាពដែលត្រូវនឹងចំណង់ចំណូលចិត្តរបស់ខ្ញុំរឺទេ?

Carrier Development Workshop
Organized by ARD
12

- ទោះបីជាបេក្ខជនគ្មានគុណសម្បត្តិដែលឆ្លើយតបទៅនឹងតំរូវការគ្រប់ចំនុចរបស់គេក៏ដោយ បេក្ខជននៅតែអាចដាក់ពាក្យធ្វើការងារនោះបាន ប្រសិនបើយើងប្រាកដ ក្នុងចិត្តថាយើងអាចធ្វើការងារនោះបាន ។
- នៅពេលដែលអ្នកសំរេចចិត្តដាក់ពាក្យធ្វើការងារនៅអង្គភាពណាហើយ អ្នកត្រូវព្យាយាមសិក្សា និងស្វែងយល់អោយបានច្រើនតាមលទ្ធភាពដែលអាចធ្វើបាន អំពីក្រុមហ៊ុននោះ ដោយសួរនាំអ្នកផ្សេងៗទៀតដែលដឹងអំពីអង្គភាពនោះ ។ ពតិមានសំខាន់ៗ ដែលអ្នកត្រូវដឹង រួមមាន :

  - បេសកកម្ម គោលដៅ និងគោលការណ៍សំខាន់ៗរបស់អង្គភាពនោះ
  - សកម្មភាពការងារ ទីតាំងគោលដៅ និងអ្នកទទួលផលដែលអ្នកត្រូវការធ្វើជាមួយ
  - បរិយាកាសការងារ និងក្រុមបុគ្គលិកដែលអ្នកត្រូវធ្វើការងារជាមួយ

Carrier Development Workshop
Organized by ARD 13

## អំពីប្រវត្តិរូបសង្ខេប និងការដាក់ពាក្យធ្វើការងារ

- ប្រវត្តិរូប គឺជាចំនុចសំខាន់សំរាប់គណៈកម្មការជ្រើសរើសពិនិត្យ និងសំរេចថាតើបេក្ខជននោះសមស្រប រឺមិនសមស្របសំរាប់មុខតំណែងការងារនេះ?
- ចំនុចសំខាន់ៗ ដែលត្រូវបញ្ចូលទៅក្នុងប្រវត្តិរូបសង្ខេប :

១. ពតិមានផ្ទាល់ខ្លួន ( ឈ្មោះ, ភេទ, អាស័យដ្ឋានទំនាក់ទំនង, សញ្ជាតិ, ទីកន្លែង និងថ្ងៃខែឆ្នាំកំណើត, ស្ថានភាព : នៅលីវ រឺមានគ្រួសារ)

២. កំរិតវប្បធម៌ : ចំណេះដឹងទូទៅ, កំរិតមហាវិទ្យាល័យ

៣. ការបណ្តុះបណ្តាលជំនាញខ្លីៗផ្សេងទៀត

Carrier Development Workshop
Organized by ARD 14

១. បទពិសោធន៍ការងារ :

  - កាលបរិច្ឆេទធ្វើការងារ
  - មុខតំណែង និងទីតាំងការងារ
  - អង្គភាពធ្វើការងារ
  - ការទទួលខុសត្រូវសំខាន់ៗ

២. ភាសា ( កំរិតនៃការប្រើប្រាស់ភាសាផ្សេងៗ)

៣. ចំណង់ចំណូលចិត្ត

Carrier Development Workshop
Organized by ARD 15

៤. អ្នកអះអាងគុណសម្បត្តិ ( រកអ្នកដែលស្គាល់ពីគុណសម្បត្តិការងារយើងច្បាស់លាស់, អ្នកដែលមានបទពិសោធន៍ការងារយូរឆ្នាំ, តំណែង និងកេរ្តិ៍ឈ្មោះល្អនៅក្នុងបរិបទការងារ ជាការល្អប្រសើរ) ។

- ប្រវត្តិរូបត្រូវតែមានរបៀបរៀបរយ និងសណ្តាប់ធ្នាប់ល្អ ដែលគួរអោយទាក់អារម្មណ៍របស់គណៈកម្មការ ។
- មិនត្រូវបំផ្លើសពីការពិតនៅក្នុងប្រវត្តិរូបសង្ខេបឡើយ ដោយធានាថារាល់អ្វីៗដែលអះអាងនៅក្នុងប្រវត្តិរូប ត្រូវតែមានឯកសារច្បាស់លាស់ ដើម្បីបង្ហាញដល់គណៈកម្មការនៅពេលត្រូវការ ។

Carrier Development Workshop
Organized by ARD 16

- ក្នុងករណីដែលមិនសូវមានបទពិសោធន៍ការងារ ប្រវត្តិរូប ត្រូវរំលេចអោយឃើញនូវចំនុចលំអិតៗ អោយបានច្រើនទាក់ទងនឹងសកម្មភាព ដែលយើងបានរៀន និងចូលរួមក្នុងកំឡុងពេលសិក្សានៅមហាវិទ្យាល័យ ។ ឧទាហរណ៍ :

  - មុខវិជ្ជាសំខាន់ៗ ដែលទាក់ទងនឹងការងារដែលត្រូវដាក់ពាក្យ ( អភិវឌ្ឍន៏ជនបទ, ការវាយតំលៃជនបទដោយមានការចូលរួម, ការផ្សព្វផ្សាយ....)
  - ការចុះកម្មសិក្សា និងបទពិសោធន៍ការងារស្ម័គ្រចិត្តផ្សេងៗ : ការចុះសិក្សាអង្កេតពីកំរិតជីវភាពគ្រួសារកសិករ, ការចុះសិក្សាអង្កេតពីការធ្វើស្រូវប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ...) ។

Carrier Development Workshop
Organized by ARD 17

## អំពីលិខិតដាក់ពាក្យធ្វើការងារ

- លិខិតដាក់ពាក្យធ្វើការងារ គឺជាចំនុចសំខាន់មួយទៀតសំរាប់គណៈកម្មការជ្រើសរើសពិនិត្យ និងសំរេច ថាតើបេក្ខជននោះសមស្រប រឺមិនសមស្របសំរាប់មុខតំណែងការងារនេះ?
- លិខិតដាក់ពាក្យធ្វើការងារ ជាឯកសារសំខាន់ជួយអោយនិយោជកមានគំនិតចំពោះលក្ខណៈពិសេសរបស់អ្នក និងស្គាល់អ្នកជាអ្នកណា ។ វាជាឯកសារសំខាន់បំផុតដែលអាចធ្វើអោយមានភាពខុសគ្នា រវាងបេក្ខជនដាក់ពាក្យធ្វើការងារដែលមានបទពិសោធន៏ដូចគ្នា ។

Carrier Development Workshop
Organized by ARD 18

- ចំនុចសំខាន់ៗ ដែលត្រូវសរសេរនៅក្នុងលិខិតដាក់ពាក្យធ្វើការងារ :

- សរសេរអោយច្បាស់ពីតំណែង អង្គភាព និងទីតាំងការងារ ដែលអ្នកកំពុងដាក់ពាក្យសុំ

- សំដែងអោយឃើញពីការចាប់អារម្មណ៍ និងការជំរុញទឹកចិត្តដែលនាំអោយអ្នកចង់ធ្វើការងារនេះ (ការបង្កើនបទពិសោធ៌, ការផ្លាស់ប្តូរបរិយាកាសការងារ, ទីតាំងការងារប្រសើរ, ត្រូវនឹងជំនាញបទពិសោធន៍របស់ខ្លួន...)

- បង្ហាញអោយឃើញពីចំណេះដឹង បទពិសោធន៍ដែលអ្នកមាន ហើយដែលធ្វើអោយអ្នកគឺជាបេក្ខជនល្អសំរាប់ការងារនេះ (រៀបរាប់សង្ខេបខ្លីៗនូវបទពិសោធន៍ ការទទួលខុសត្រូវនៃការងាររបស់អ្នកកន្លងមក ដែលពាក់ព័ន្ធទៅនឹងការងារដែលអ្នកកំពុងដាក់ពាក្យ) ។

Carrier Development Workshop
Organized by ARD
19

## ឯកសារផ្សេងៗដែលត្រូវភ្ជាប់ជាមួយ

- ឯកសារផ្សេងៗដែលត្រូវភ្ជាប់ជាមួយនៅពេលដាក់ពាក្យធ្វើការងារ គឺអាចប្រែប្រួលទៅតាមអង្គភាព-ស្ថាប័ននីមួយៗ ។ ឯកសារទាំងនោះ មាន :

- សញ្ញាប័ត្រ និងវិញ្ញាប័នប័ត្របញ្ជាក់ការសិក្សាផ្សេងៗ

- លិខិតបញ្ជាក់ពីគុណសម្បត្តិការងារកន្លងមក

- ទំរង់បំពេញពាក្យសុំការងារ

- ក្នុងករណីដែលអ្នកទើបតែចាប់ផ្តើមការងារដំបូង រឺមានបទពិសោធន៍ការងារតិច ជាការប្រសើរត្រូវភ្ជាប់ជាមួយនូវឯកសារទាំងអស់ដែលអ្នកមាន ។

Carrier Development Workshop
Organized by ARD
20

- អង្គភាពខ្លះ តំរូវអោយផ្ញើនូវរាល់ឯកសារសំរាប់ដាក់ពាក្យធ្វើការងារ តាមរយៈការិយាល័យ រឺប្រអប់សំបុត្ររបស់គេផ្ទាល់តែម្តង ករណីនេះអ្នកមិនត្រូវផ្ញើតាមរយៈសារអេឡិចត្រូនិចឡើយ ។

- រាល់ឯកសារដាក់ពាក្យធ្វើការងារ ត្រូវដាក់នៅក្នុងសឺមីដែលមានការខ្ទងត្រឹមត្រូវ និងច្បាស់លាស់អំពី :

- ឈ្មោះ អាសយដ្ឋានទំនាក់ទំនងរបស់បេក្ខជន

- គោលបំណងនៃឯកសាររបស់អ្នក (ដាក់ពាក្យសុំធ្វើការងារក្នុងតំណែង...)

- ឈ្មោះ អាសយដ្ឋានទំនាក់ទំនងរបស់អង្គភាព-ស្ថាប័នដែលអ្នកផ្ញើទៅ ។

Carrier Development Workshop
Organized by ARD
21

## ការត្រៀមខ្លួនដើម្បីប្រកួតប្រជែង (សំណួរសរសេរ_សំភាសន៍)

- នៅពេលដែលត្រូវបានជូនដំណឹង ដើម្បីចូលរួមប្រកួតប្រជែងហើយ អ្នកត្រូវ

- សិក្សាឡើងវិញអំពីសេចក្តីជូនដំណឹងជ្រើសរើសបុគ្គលិក (ជាពិសេសការទទួលខុសត្រូវ និងលក្ខ័ណ្ឌការងារ)

- ពិនិត្យមើលឡើងវិញអំពីប្រវត្តិរូបរបស់យើង និងចងចាំអោយច្បាស់ពីអ្វីដែលយើងបានសរសេរនៅក្នុងនោះ

- សិក្សាអោយស្គាល់ទីតាំងដែលត្រូវសំភាសន៍អោយបានច្បាស់លាស់

- សិក្សា និងសាកសួរអោយដឹងពត៌មានខ្លះៗអំពីតំណែងការងារ និងអង្គភាពដែលយើងដាក់ពាក្យធ្វើការងារ តាមដែលអាចធ្វើទៅបាន

Carrier Development Workshop
Organized by ARD
22

- ត្រៀមសំណួរសំខាន់ៗ និងស្វែងរកចំលើយដែលត្រូវឆ្លើយ ។ សំណួរទូទៅ ដែលជាញឹកញាប់ ត្រូវបានគេសួរនៅក្នុងពេលសំភាសន៍ គឺ :

១. សូមរៀបរាប់អំពីបទពិសោធន៍របស់អ្នកកន្លងមក

២. ហេតុអ្វី បានជាអ្នកចាប់អារម្មណ៍នឹងការងារនេះ?

៣. តើអ្វីខ្លះដែលអ្នកគិតថាជាចំនុចខ្លាំង-ចំនុចខ្សោយរបស់អ្នក?

Carrier Development Workshop
Organized by ARD
23

៤. របៀប និងគុណសម្បត្តិនៃការធ្វើការងារជាក្រុម?

៥. របៀបនៃការដោះស្រាយបញ្ហាដែលអ្នកជួបប្រទះ?

៦. ចំណេះដឹងអំពីយេនឌ័រ?

៧. ក្រៅពីនេះអ្នកត្រូវយកចិត្តទុកដាក់នឹងសំណួរជាច្រើនផ្សេងទៀត ដែលទាក់ទងនឹងការងារដែលអ្នកដាក់ពាក្យផ្ទាល់ ។

Carrier Development Workshop
Organized by ARD
24

## ចំនុចសំខាន់ៗ និងអាកប្បកិរិយា ដែលត្រូវប្រកាន់យក ក្នុងពេលសំភាសន៍

- អ្នកត្រូវមកដល់ទីកន្លែងដែលត្រូវណាត់ជួបសំភាសន៍អោយបានយ៉ាងហោចណាស់១៥ នាទីមុន ដើម្បីអ្នកអាចសំរួលអារម្មណ៍បានល្អមុនពេលចូលសំភាសន៍
- មិនត្រូវមានសំពាយសំពីងសំពោងនៅពេលចូលក្នុងបន្ទប់សំភាសន៍ឡើយ ។ ពេលចូលដល់បន្ទប់សំភាសន៍ ត្រូវជំរាបសួរនូវរាល់សមាជិកគណៈកម្មការ ។

Carrier Development Workshop
Organized by ARD
25

- គួរស្លៀកពាក់អោយបានសមរម្យ និងឆ្លើយតបបានទៅនឹងតំណែងការងារ ( មិន ត្រូវឆើតឆាយពេក, ពាក់គ្រឿងអលង្កាហួសហេតុ...)
- របៀបអង្គុយពេលសំភាសន៍ អ្នកត្រូវដាក់ដៃទាំងពីរលើភ្លៅរបស់អ្នក រឺដាក់លើតុ ។ ជៀសវៀងការអង្គុយផ្អែកខ្នាំងទៅនឹងកៅអីផ្អែក, អង្រួនជើង, គោះ រឺលើកដៃចុះឡើង... ។

Carrier Development Workshop
Organized by ARD
26

- ជាការប្រសើរ នៅមុនពេលឆ្លើយសំណួរនីមួយៗ អ្នកត្រូវឆ្លៀតប្រើប្រាស់នូវពាក្យសំដីដែលបង្ហាញអំពីការអរគុណចំពោះអ្នកសួរ ។ ក្នុងករណីដែលអ្នកស្តាប់មិនបានច្បាស់ រឺមិនសូវយល់ចំពោះសំណួរ អ្នកត្រូវសួរបញ្ជាក់អោយអ្នកសួរបញ្ជាក់ជាថ្មីម្តងទៀត ជៀសវាងការឆ្លើយទាំងស្រពិចស្រពិល ដែលអាចចាកប្រធាន ។

Carrier Development Workshop
Organized by ARD
27

- ព្យាយាមឆ្លើយនូវរាល់សំណួរទាំងឡាយអោយបានច្បាស់លាស់ និងមានបំណកស្រាយបន្ថែមដើម្បីគាំទ្រដល់ចំលើយរបស់អ្នក ។
- នៅពេលសំភាសន៍ អ្នកត្រូវប្រើប្រាស់ភ្នែករបស់អ្នកសំលឹងទៅរកគ្រប់គណៈកម្មការសំភាសន៍ ដើម្បីបង្ហាញអោយឃើញពីការចាប់អារម្មណ៏របស់អ្នកចំពោះពួកគេ ។

Carrier Development Workshop
Organized by ARD
28

- អ្នកអាចសួរគណៈកម្មាការ ប្រសិនបើអ្នកត្រូវបានផ្តល់ឱកាសចុងក្រោយដើម្បីសួរសំណួរ ។ សំណួរដែលអ្នកគួរសួរ គឺត្រូវតែពាក់ព័ន្ធផ្ទាល់ទៅនឹងតំណែងការងារដែលកំពុងដាក់ពាក្យ ហើយគួរសួរតែ ១-៣ សំណួរបានហើយ ។
- នៅពេលបញ្ចប់ការសំភាសន៍ អ្នកត្រូវនិយាយថ្លែងអំណរគុណដល់គណៈកម្មការដែលបានអនុញ្ញាតិ និងចំណាយពេលសំរាប់អ្នក ដើម្បីសំភាសន៍ និងជំរាបលា ។

Carrier Development Workshop
Organized by ARD
29

- ត្រូវចងចាំថា ការសំភាសន៍ គឺជាកត្តាកំណត់សំខាន់បំផុតទៅលើលទ្ធផលស្វែងរកការងាររបស់អ្នក ។ ប្រសិនបើបេក្ខជនមានចំណេះដឹង និងបទពិសោធន៏ប្រហាក់ប្រហែលគ្នាប៉ុន្តែអ្នកមានអាកប្បកិរិយាល្អ សំដែងអោយឃើញពីការធ្វើការងារជាក្រុមល្អ, ការតាំងចិត្តខ្ពស់ក្នុងការធ្វើការងារ, បង្ហាញពីចំណង់រៀនបន្ថែមអ្វីដែលថ្មី...) ។

Carrier Development Workshop
Organized by ARD
30


ចំនុចសំខាន់ៗដែលជួយអោយអាជីព
ការងារទទួលបានជោគជ័យ  និងរីកចំរើន
អ្នកត្រូវចងចាំជានិច្ចថា ការរកការងារបានធ្វើមិនទាន់ជាករណីអស្ចារ្យនោះនៅឡើយទេ ប៉ុន្តែបន្ទាប់ពីបានការងារហើយ ការរក្សានូវមុខតំណែងការងារនោះអោយបានជាប់លាប់ឋិតថេរ, ការបង្កើតជំនឿទុកចិត្តដល់អ្នករួមការងារ និងអ្នកគ្រប់គ្រងរបស់ខ្លួន, និងការធ្វើអោយការងាររបស់យើងមានការរីកចំរើន ទើបជាកត្តាមួយដែលល្អ និងបង្ហាញពីសមត្ថភាពពិតប្រាកដរបស់អ្នក ។
Carrier Development Workshop
Organized by ARD
31


ចំនុចសំខាន់ៗ ដើម្បីអភិវឌ្ឍន៍អាជីពការងារ :
១. បំពេញការងារដោយមានការទទួលខុសត្រូវខ្ពស់
២. គោរពគោលការណ៍ និងពេលវេលារបស់អង្គភាពអោយបានខ្ជាប់ខ្ជួន
៣. ព្យាយាមបង្កើតការងារដោយខ្លួនឯង (គំនិតផ្តួចផ្តើម) មិនរង់ចាំតែការដាក់ការងារអោយពីអ្នកគ្រប់គ្រង
៤. ត្រូវមានឆន្ទៈ និងមនសិការទៀងត្រង់ ត្រឹមត្រូវ ស្អាតស្អំ និងយុត្តិធម៌
៥. ត្រូវមានគំនិតលះបង់ខ្ពស់ ដើម្បីជាប្រយោជន៏ដល់អង្គភាពរបស់ខ្លួន
Carrier Development Workshop
Organized by ARD
32


៦. ត្រូវមានឆន្ទៈរៀនបន្ថែមនូវអ្វីដែលថ្មី និងទទួលយកនូវគំនិតកែលំអនានាពីមជ្ឈដ្ឋានទូទៅ
៧. ត្រូវរៀនសង្កេត និងយកគំរូតាមនូវរបៀបរបបការងារដែលល្អពីអ្នករួមការងារ រឺពីមជ្ឈដ្ឋានផ្សេងៗ
៨. ត្រូវមានសេចក្តីក្លាហាន និងសំលឹងមើលអំពីតំណែងការងារដែលខ្ពស់ជាងបច្ចុប្បន្ន និងធ្វើផែនការដើម្បីឈោងចាប់នូវការងារនោះតាមជំហានៗ
៩. ព្យាយាមបង្កើត និងបង្កើទំនាក់ទំនងល្អជាមួយអ្នករួមការងារ, ជាមួយអង្គភាពការងារផ្សេងៗទៀត ដើម្បីបង្កើតជំនឿទុកចិត្តដល់អ្នកទាំងនោះ ។
Carrier Development Workshop
Organized by ARD
33


សូមអរគុណ  ចំពោះការចូលរួម
ស្តាប់របស់លោកអ្នក  !!!
Carrier Development Workshop
Organized by ARD
34


សូមជូនពរដល់លោកអ្នក  អោយទទួល
បានជោគជ័យនៅក្នុងអាជីពការងារ  !!!
Carrier Development Workshop
Organized by ARD
35